**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

**អគ្គនាយកដ្ឋានអាស៊ាន**

សេចក្តីប្រកាសព័ត៌មាន

**លទ្ធផលនៃកិច្ចប្រជុំកំពូលអាស៊ានលើកទី៤២**
**នៅទីក្រុងឡាប៊ូនបាចូ សាធារណរដ្ឋឥណ្ឌូនេស៊ី**
**ថ្ងៃទី១០-១១ ខែឧសភា ឆ្នាំ២០២៣**

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣ - តបតាមការអញ្ជើញរបស់**ឯកឧត្តម ចូកូ វីដូដូ** ប្រធានាធិបតីនៃសាធារណរដ្ឋឥណ្ឌូនេស៊ី និងជាប្រធានអាស៊ានឆ្នាំ២០២៣ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានអញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់កម្ពុជា ចូលរួមកិច្ចប្រជុំកំពូលអាស៊ានលើកទី៤២ និងកិច្ចប្រជុំពាក់ព័ន្ធ ដែលបានប្រព្រឹត្តទៅថ្ងៃទី១០-១១ ខែឧសភា ឆ្នាំ២០២៣ នៅទីក្រុងឡាប៊ូនបាចូ។

នៅក្នុងឱកាសនៃកិច្ចប្រជុំកំពូលទាំងនេះ ប្រមុខដឹកនាំអាស៊ានបានបញ្ជាក់នូវការគាំទ្រចំពោះភាពជាប្រធានរបស់ឥណ្ឌូនេស៊ី ក្រោមមូលបទ៖ "**សារៈសំខាន់អាស៊ាន៖ ស្នូលនៃកំណើន**" និងបានសម្តែងនូវសេចក្តីពេញចិត្តចំពោះវឌ្ឍនភាព ក្នុងការសម្រេចបាននូវអាទិភាពរបស់អាស៊ានសម្រាប់ឆ្នាំ២០២៣ ជាពិសេស ក្នុងការប្រែក្លាយអាស៊ានទៅជាសហគមន៍មួយដែលមានស្ថាប័នប្រកបដោយភាពស្វាហាប់ រឹងមាំ និងពោរពេញទៅដោយសមត្ថភាពនិងប្រសិទ្ធភាព។

ប្រមុខដឹកនាំអាស៊ានក៏បានស្វាគមន៍អាទិភាព និងគំនិតផ្តួចផ្តើមទាំងឡាយរបស់ឥណ្ឌូនេស៊ី មានជាអាទិ៍៖ (១) ការស្តារនិងកសាងឡើងវិញ (២) សេដ្ឋកិច្ចឌីជីថល និង (៣) ចីរភាព។ ប្រមុខដឹកនាំអាស៊ានបានប្តេជ្ញាចិត្តនឹងធ្វើឲ្យអាស៊ានក្លាយជាចលករនៃកំណើនសាកល និងជាកម្លាំងជំរុញសម្រាប់សន្តិភាព តាមរយៈសមាហរណកម្មសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន ដំណើរការបន្លាស់ឌីជីថល ការអភិវឌ្ឍប្រកបដោយចីរភាព ស្ថិរភាពហិរញ្ញវត្ថុ សន្តិសុខថាមពល និងស្បៀង និងការអភិវឌ្ឍធនធានមនុស្ស។ ជាងនេះទៀត ប្រមុខដឹកនាំអាស៊ានបានសង្កត់ធ្ងន់លើសារៈសំខាន់ក្នុងការធ្វើការជាមួយដៃគូនានា ដើម្បីជំរុញការអនុវត្តទស្សនវិស័យអាស៊ានស្តីពីឥណ្ឌូ-ប៉ាស៊ីហ្វិក តាមរយៈគម្រោងជាក់លាក់ទាំងឡាយ និងកិច្ចសហប្រតិបត្តិការជាក់ស្តែង។

អាសយដ្ឋាន៖ លេខ ៣ វិថី **សម្តេច ហ៊ុន សែន**
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

ប្រមុខដឹកនាំបានអះអាងជាថ្មីនូវការប្តេជ្ញាចិត្តបន្តពង្រឹងមជ្ឈភាព និងឯកភាពអាស៊ាន ក្នុងការធ្វើទំនាក់ទំនងជាមួយដៃគូខាងក្រៅនានា ក្នុងពេលដែលមានភាពមិនប្រាកដប្រជាដ៏ធំ ហើយដែលសណ្តាប់ធ្នាប់តំបន់ និងពិភពលោកកំពុងមានការវិវត្តយ៉ាងឆាប់រហ័ស។ កិច្ចប្រជុំកំពូលក៏បានសង្កត់ធ្ងន់អំពីសារៈសំខាន់នៃសន្ធិសញ្ញាមិត្តភាពនិងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ (TAC) ក្នុងការគ្រប់គ្រងទំនាក់ទំនងអន្តររដ្ឋ និងការរក្សាសន្តិភាព សន្តិសុខ និងស្ថិរភាព ក្នុងតំបន់។ ប្រមុខដឹកនាំអាស៊ានបានស្វាគមព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត ប្រទេសប៉ាណាម៉ា និងម៉ិកស៊ិក ចូលជាភាគីនៃ TAC ហើយសង្ឃឹមថា ការចុះហត្ថលេខាដោយប្រទេសទាំងបីនេះចូលជាភាគីនៃ TAC នឹងអាចប្រព្រឹត្តទៅនៅក្នុងឆ្នាំ២០២៣នេះ។

ប្រមុខដឹកនាំអាស៊ានក៏ទន្ទឹងរង់ចាំផងដែរនូវការរៀបចំកិច្ចប្រជុំកំពូលរំលឹកខួបអនុស្សាវរីយ៍អាស៊ាន-ជប៉ុនលើកទី ៥០ នៃទំនាក់ទំនងមិត្តភាព និងសហប្រតិបត្តិការអាស៊ាន-ជប៉ុន ថ្ងៃទី១៦-១៨ ខែធ្នូ ឆ្នាំ២០២៣ នៅទីក្រុងតូក្យូ និងការរៀបចំកិច្ចប្រជុំកំពូលពិសេសដើម្បីរំលឹកខួបអនុស្សាវរីយ៍លើកទី៥០ នៃទំនាក់ទំនងកិច្ចដៃគូសន្ទនាអាស៊ាន-អូស្ត្រាលី ក្នុងខែមីនា ឆ្នាំ២០២៤ នៅអូស្ត្រាលី។ លើសពីនេះទៀត ប្រមុខដឹកនាំក៏បានស្វាគមន៍លើសំណើរៀបចំកិច្ចប្រជុំកំពូលអាស៊ាន-ក្រុមប្រឹក្សាសហប្រតិបត្តិការឈូងសមុទ្រ ក្នុងឆមាសទី២ នៃឆ្នាំនេះ ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងរីយ៉ាដ ព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត។

ក្នុងឱកាសនៃកិច្ចប្រជុំកំពូលអាស៊ានលើកទី៤២ **សម្តេចតេជោនាយករដ្ឋមន្ត្រី** រួមជាមួយនឹងប្រមុខរដ្ឋដឹកនាំអាស៊ានដទៃទៀត ក៏បានអញ្ជើញចូលរួមកិច្ចប្រជុំប្រមុខដឹកនាំអាស៊ានជាមួយតំណាងអន្តរសភាអាស៊ាន (AIPA) កិច្ចប្រជុំប្រមុខដឹកនាំអាស៊ានជាមួយតំណាងយុវជនអាស៊ាន កិច្ចប្រជុំប្រមុខដឹកនាំអាស៊ានជាមួយតំណាងក្រុមប្រឹក្សាផ្តល់យោបល់ធុរកិច្ចអាស៊ាន និងកិច្ចប្រជុំប្រមុខដឹកនាំអាស៊ាន ជាមួយក្រុមការងារជាន់ខ្ពស់ចក្ខុវិស័យសហគមន៍អាស៊ានក្រោយឆ្នាំ២០២៥។ នៅក្នុងកិច្ចប្រជុំទាំងនេះ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់នូវចំណុចសំខាន់ៗ ដូចខាងក្រោម៖

- អាស៊ានត្រូវឆ្លើយតបចំពោះបញ្ហាប្រឈមទាំងឡាយទាំងនៅក្នុងតំបន់ និងសាកលលោក ឱ្យបានទាន់ពេលវេលា ប្រកបដោយប្រសិទ្ធភាព និងបុរេសកម្ម ជាពិសេសបញ្ហាដែលអាស៊ានពុំអាចទទួលបានកុងសង់ស៊ីស ដោយមិនទុកឱ្យបញ្ហាទាំងនោះប៉ះពាល់ដល់ដំណើរការកសាងសហគមន៍អាស៊ាន និងសមាហរណកម្មតំបន់ឡើយ។
- ការពង្រឹងសហគមន៍អាស៊ានមិនត្រូវធ្វើឲ្យប៉ះពាល់ដល់គោលការណ៍គ្រឹះទាំងឡាយ ដែលមានចែងក្នុងធម្មនុញ្ញអាស៊ានឡើយ ជាពិសេស គោលការណ៍ស្តីពីការធ្វើសេចក្តីសម្រេចចិត្តដោយផ្អែកលើការពិគ្រោះយោបល់និងកុងសង់ស៊ីស និងការមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងផងគ្នា។

- ចក្ខុវិស័យសហគមន៍អាស៊ានក្រោយឆ្នាំ២០២៥ ត្រូវឆ្លើយតបចំពោះនិន្នាការតំបន់ និងសាកល ដែលកំពុងមានការវិវត្តយ៉ាងឆាប់រហ័ស ដូចជារបៀបវារៈបៃតង សេដ្ឋកិច្ចឌីជីថល បច្ចេកវិទ្យាទំនើប ខ្សែចង្វាក់តម្លៃសកល ការតភ្ជាប់ការដឹកជញ្ជូន និងភស្តុភាជាដើម ក្នុងបំណងធានាឲ្យបានថា អាស៊ានត្រៀមខ្លួនរួចជាស្រេច និងនៅតែរឹងមាំ ហើយធន់ នៅពេលអនាគត។
- នៅខណៈពេលដែលទទួលស្គាល់អំពីតម្រូវការ ដើម្បីរៀបចំចក្ខុវិស័យសហគមន៍អាស៊ានក្រោយឆ្នាំ២០២៥ ឲ្យបានប្រកបដោយទស្សនវិស័យវែងឆ្ងាយ ការបំផុសគំនិត និងការសំឡឹងឆ្ពោះទៅមុខ ប្រមុខដឹកនាំអាស៊ានបានគូសបញ្ជាក់នូវតម្រូវការក្នុងការធ្វើឲ្យមានតុល្យភាពរវាងភាពជាក់ស្តែងនិយម និងបំណងប្រាថ្នាដែលចង់បាន។ អ្វីដែលសំខាន់ជាងនេះទៀតនោះ គឺចក្ខុវិស័យសហគមន៍អាស៊ានក្រោយឆ្នាំ២០២៥នេះ គួរតែផ្តោតលើសកម្មភាពជាក់ស្តែង និងតម្កល់ប្រជាជនជាស្នូលនៃកិច្ចខិតខំប្រឹងប្រែង ក្នុងការកសាងសហគមន៍អាស៊ាន។
- ចំពោះបញ្ហាមីយ៉ាន់ម៉ា វាមានសារៈសំខាន់ក្នុងការធានាឱ្យបាននូវការអនុវត្តកិច្ចព្រមព្រៀងជាឯកច្ឆន្ទ៥ចំណុច និងការពិនិត្យឡើងវិញ និងសេចក្តីសម្រេចរបស់ប្រមុខដឹកនាំអាស៊ានដែលបានអនុម័តនៅឆ្នាំ២០២២កន្លងមក ឱ្យបានពេញលេញ និងប្រកបដោយប្រសិទ្ធភាព។ លើសពីនេះ អាស៊ានគួរប្រកាន់ខ្ជាប់នូវភាពអត់ធ្មត់ ភាពបត់បែន និងការច្នៃប្រឌិតខ្ពស់ ហើយស្វែងរកវិធីសាស្ត្រណាដែលមានសក្តានុពល អាចជួយមីយ៉ាន់ម៉ាស្តារសន្តិភាព និងត្រឡប់ទៅរកប្រក្រតីភាពឡើងវិញ។
- នៅក្នុងបរិបទនៃការប្រកួតប្រជែងភូមិសាស្ត្រនយោបាយ និងសេដ្ឋកិច្ច អាស៊ានត្រូវលើកកម្ពស់ភាពពាក់ព័ន្ធរបស់ខ្លួន ហើយត្រូវពង្រឹងយន្តការទាំងឡាយដែលដឹកនាំដោយអាស៊ាន ដើម្បីធ្វើយ៉ាងណាឱ្យអាស៊ានបន្តដើរតួនាទីស្នូល និងនាំមុខ ក្នុងការដោះស្រាយការប្រឈមនានា ក្នុងតំបន់ និងសកលលោក។ កម្ពុជាក៏បានរំលេចផងដែរថា អាស៊ានគួរស្វាគមន៍គំនិតផ្តួចផ្តើមទាំងឡាយណារបស់ដៃគូខ្លួន ដរាបណាគំនិតផ្តួចផ្តើមទាំងនោះស្របតាមធម្មនុញ្ញអាស៊ាន និងគោលការណ៍នៃទស្សនវិស័យអាស៊ានស្តីពីឥណ្ឌូ-ប៉ាស៊ីហ្វិក (AOIP) និងរួមចំណែកដល់សន្តិភាព ស្ថិរភាព និងវិបុលភាព នៅក្នុងតំបន់ ហើយមិនត្រូវយកទៅប្រើប្រាស់ ដើម្បីប្រឆាំងនឹងភាគីដទៃទៀតឡើយ។

ប្រមុខដឹកនាំអាស៊ានបានស្វាគមន៍ការចូលរួមលើកដំបូងរបស់ **ឯកឧត្តម ឡូរ ម៉ាតាន់ រូអាក់** នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្ត ក្នុងកិច្ចប្រជុំកំពូលអាស៊ាន បន្ទាប់ពីប្រមុខដឹកនាំអាស៊ានបានឯកភាពគ្នាជាគោលការណ៍អនុញ្ញាតឱ្យប្រទេសនេះក្លាយជាសមាជិកទី១១របស់អាស៊ាន។

ក្នុងកំឡុងពេលស្នាក់នៅនៅក្រុងឡាប៊ូនបាចូ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានជួបសម្តែងការគួរសមជាមួយ**ឯកឧត្តម ចូកូ វីដូដូ** ប្រធានាធិបតី នៃសាធារណរដ្ឋឥណ្ឌូនេស៊ី។ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ក៏បានជួបពិភាក្សាទ្វេភាគីដាច់ដោយឡែកផងដែរជាមួយ **ឯកឧត្តម ផាំ មិញជិញ** នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋសង្គមនិយមវៀតណាម និង**ឯកឧត្តមនាយករដ្ឋមន្ត្រី ទូរ ម៉ាតាន់រូអាក់** ដោយបានផ្លាស់ប្តូរទស្សនៈលើបញ្ហាជាច្រើន ដែលមានសារៈសំខាន់ជាយុទ្ធសាស្ត្រចំពោះអាស៊ាន និងទំនាក់ទំនងទ្វេភាគីជាមួយប្រទេសទាំងពីរនេះ៕